REPRODUCTIVE HEALTH
ASSOCIATION OF CAMBODIA

# ដំណឹងជ្រើសរើសបុគ្គលិក

សមាគមថែទាំសុខភាពគ្រួសារកម្ពុជា " រ៉ាក់ " គឺជាអង្គការក្រៅរដ្ឋាភិបាលមួយ កំពុងធ្វើការផ្តោតលើសេវាសុខភាពគ្រួសារ ដែលរួមមានសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ សុខភាពមាតា ទារក និងកុមារ ជំងឺរបេង មេរោគ អេដស៍/ជំងឺអេដស៍ និងសុខភាពយុវវ័យ ។ ថ្មីៗ នេះសមាគមរ៉ាក់បានទទួលគំរោងថ្មីមួយឈ្មោះថា **"រួមគ្នាដើម្បីសុខភាពល្អ "** ក្រោមថវិកាឧបត្ថម្ភរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីកិច្ចអភិវឌ្ឍន៍អន្តរជាតិ (USAID) សំរាប់ រយៈពេល៥ឆ្នាំ ដែលនឹងត្រូវអនុវត្តតាមបណ្តាខេត្តក្រុងមួយចំនួនដូចជា រាជធានីភ្នំពេញ ក្រុងព្រះសីហនុ ខេត្តកំពង់ចាម តាកែវ បាត់ដំបង សៀមរាប ប៉ៃលិន កំពង់ស្ពឺ និងស្វាយរៀង ។

សមាគមរ៉ាក់ត្រូវការជ្រើសរើសបុគ្គលិកសំរាប់បំរើការងារកម្មវិធីអេដស៍នៃក្រុមងាយរងគ្រោះ ដូចខាងក្រោម:

## ជំនួយការកម្មវិធី (Project Assistant)

### សំរាប់កម្មវិធីអេដស៍នៃក្រុមងាយរងគ្រោះចំនួន១នាក់នៅក្រុងភ្នំពេញ

**សង្ខេបភារកិច្ចទទួលខុសត្រូវ:**

- រៀបចំផែនការ បណ្តុះបណ្តាល អប់រំ និង បញ្ជូនក្រុមគោលដៅទៅរកសេវាកម្មគ្លីនិក

**បេក្ខជនត្រូវមានលក្ខណ:សម្បត្តិ:**

- បរិញ្ញាប័ត្រផ្នែក វិទ្យាសាស្ត្រសង្គម ឬ វិទ្យាសាស្ត្រសុខាភិបាល ឬ សញ្ញាប័ត្រសមមូល
- មានបទពិសោធន៍ធ្វើការងារ២ឆ្នាំជាមួយគំរោងសុខភាពបន្តពូជរួមទាំងមេរោគអេដស៍ និងជំងឺអេដស៍ ។
- មានចំណេះដឹងល្អស្តីពីវិធីសាស្ត្រនៃការអប់រំ និងបណ្តុះបណ្តាលតាមបែបចូលរួម គឺជាការចាំបាច់ ។
- មានចំណេះដឹងភាសាអង់គ្លេស និង កុំព្យូទ័រ ( Word & Excel).
- មានជំនាញល្អ ក្នុងការបណ្តុះបណ្តាល និងទំនាក់ទំនងរវាងបុគ្គល ។
- មានឆន្ទ:ធ្វើការបត់បែនតាមពេលវេលា កាលៈទេសៈ ។
- មានអាកប្បកិរិយា និង សីលធម៌ល្អ និងការប្តេជ្ញាចិត្តខ្ពស់ចំពោះការងារ ។

បេក្ខជន បេក្ខនារីដែលមានចំណាប់អារម្មណ៍ សូមអញ្ជើញដាក់ពាក្យមកការិយាល័យបុគ្គលិកនៅស្នាក់ការកណ្តាលរបស់សមាគម រ៉ាក់ ផ្ទះលេខ១៤ ផ្លូវលេខ៣១៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក ក្រុងភ្នំពេញ ដោយភ្ជាប់ជាមួយនូវប្រវត្តិរូបសង្ខេប ឯកសារពាក់ព័ន្ធ និងរូបថត (៤ X ៦) ចំនួន១សន្លឹកឬ E-mail to: hr@rhac.org.kh **(Do not attach copies of certificates to the e-mail but bring them to the interview)** ។ ពត៌មានលំអិត សូមទំនាក់ទំនងទូរស័ព្ទលេខ ០២៣ ៨៨៥ ១៣៥ ។

***ចាប់ផ្តើមទទួលពាក្យចាប់ពីថ្ងៃផ្សាយដំណឹងនេះរហូតដល់ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០០៩ វេលាម៉ោង ៥ល្ងាច ។***

បញ្ជាក់: - សូមសរសេរ ***អំពីតួនាទី និងទីកន្លែង*** ដែលដាក់ពាក្យស្នើសុំធ្វើការងារអោយបានច្បាស់លាស់

- ឯកសារនិងពាក្យដែលបានដាក់មកសមាគមរ៉ាក់មិនអាចដកវិញបានទេ